# អង្គរបុរី
## សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ភាពខុសគ្នានៃព្រះពុទ្ធសាសនាហីនយាន និងព្រះពុទ្ធសាសនាមហាយាន ។

website: www.hoksavann.org

ថ្ងៃទី២ មីនា ២០០៨



ព្រះពុទ្ធសាសនាមាននិកាយពីរ គឺព្រះពុទ្ធសាសនាថេរវាទ ឬហីនយាន និងព្រះពុទ្ធសាសនាអាចរិយ ឬមហាយាន ។

ព្រះពុទ្ធសាសនាថេរវាទ រក្សាទុកនូវធម៌វិន័យរបស់ព្រះពុទ្ធមិនកែប្រែ ដែលសព្វថ្ងៃហៅថាព្រះត្រៃបិដក ។ ប្រទេសដែលកាន់ព្រះពុទ្ធសាសនាថេរវាទមានប្រទេសកម្ពុជា, ប្រទេសលាវ, ប្រទេសស្រីលង្កា និងប្រទេសភូមាជាដើម ។

ព្រះពុទ្ធសាសនាមហាយានបានកែប្រែធម៌វិន័យរបស់ព្រះពុទ្ធ គោរពព្រះពោធិសត្វ ដូចជាព្រះពោធិសត្វ អវលោកេតិស្វរៈ មញ្ញូស្រី មេត្រេយ ប្រាជ្ញាបារមីជាដើម ។ ប្រទេសដែលកាន់ព្រះពុទ្ធសាសនាមហាយាន មានប្រទេសចិន ប្រទេសទីបេត៏ ប្រទេសជប៉ុន និងប្រទេសកូរេជាដើម ។

ភាពខុសគ្នានៃព្រះពុទ្ធសាសនាទាំងពីរនិកាយនេះ ៖

### និកាយថេរវាទ (ហីនយាន)

១- បង្រៀនឲ្យអ្នកប្រព្រឹត្តសម្លឹងយកព្រះអរហន្ត ដើម្បីរួចចាកទុក្ខ ដោយសង្កត់ធ្ងន់ចំពោះអរិយសច្ច៤ ។

២- លើកកំពស់គុណភាពអភិវឌ្ឍន៍ ក៏រិតសតិបញ្ញាសាសនិករបស់ខ្លួនឲ្យយកសាសនាជាធំ ។

៣- បង្រៀនអ្នកប្រតិបត្តិយ៉ាងតឹងរ៉ឹង តាមធម៌វិន័យរបស់ព្រះពុទ្ធ ។

៤- មិនយកពិធីកម្មសាសនាជាធំ ។

៥- គោរពប្រតិបត្តិតាមពាក្យព្រះធម៌ជាធំ ។

៦- មានការបដិរូប (កែប្រែ) ថ្មីស្តិខ្លះ តែតិចតួចបំផុត ហើយប្រកាន់យកពុទ្ធវចនៈ

៧- ជាសាសនាអទេវនិយម (មិនមែនទេវតា) គោរពប្រតិបត្តិព្រះពុទ្ធតែមួយព្រះអង្គ ។

៨- ចង្អុលបង្ហាញឲ្យជឿខ្លួនឯងជាធំ ហើយជឿកម្មនិងផលរបស់កម្ម ។

៩- និព្វាន តាមពាក្យព្រះសម្មាសម្ពុទ្ធ គឺការរលត់ទុក្ខ ហើយមិនត្រឡប់មកកើតទៀតឡើយ ។

១០- ព្រះត្រៃបិដកចារឹកក្នុងសាស្ត្រាស្លឹករិតជាភាសាបាលី ។

## និកាយអាចរិយវាទ (មហាយាន)

១- បង្រៀនឲ្យសាសនិកមានជំនឿលើព្រះពោធិសត្វ និងធ្វើកិច្ចការអ្វីៗ ដើម្បីព្រះពោធិសត្វ ។

២- បង្រៀនឲ្យមានជំនឿជឿស៊ប់ មុនពេលពង្រឹងស្មារតីនិងគុណភាព ។

៣- បង្រៀនឲ្យឃើញប្រយោជន៍និកាយខ្លួនជាធំ ទោះបីមានការប្រព្រឹត្តខុសអំពីធម៌វិន័យក៏ដោយ ។

៤- មានការផ្លាស់ប្តូរពិធីកម្មជាលំដាប់ តាមប្រទេសនិងទីកន្លែងនីមួយៗ ។

៥- មានការអធិប្បាយបន្ថែមបន្ថយពុទ្ធវចនៈជាច្រើន ។

៦- មានតែងព្រះសូត្រថ្មី និងកាត់បន្ថយព្រះសូត្រចាស់ជាច្រើន មិនប្រកាន់ភ្ជាប់នូវពុទ្ធវចនៈ ។

៧- ជាសាសនាទេវនិយម គោរពប្រតិបត្តិព្រះពុទ្ធជាច្រើនព្រះអង្គ ។

៨- ចង្អុលបង្ហាញលើកស្ទួយការបន់ស្រន់និងមានចិត្តស្នេហ៍ចំពោះព្រះពុទ្ធ ។

៩- និព្វានរបស់ព្រះពុទ្ធ មិនមែនជាការរលត់សូន្យទាំងស្រុងទេ គឺគ្រាន់តែបរិនិព្វានក្នុងស្ថានមនុស្សលោក ទៅកើតក្នុងស្ថានសួគ៌ទេវលោក ។ ពេលណាមនុស្សកើតកោឡាហល និងចុះមកកើតជាមនុស្ស ដើម្បីបង្អុលផ្លូវរំលត់ទុក្ខដល់សត្វលោកម្តងទៀត ។

១០- ព្រះត្រៃបិដកចារឹកលើផ្ទាំងមាសជាភាសាសំស្ក្រឹត ។

តាមការពន្យល់រៀបរាប់មកនេះបញ្ជាក់ថា ពុទ្ធសាសនាមហាយានបានកែប្រែធម៌វិន័យរបស់ព្រះពុទ្ធ ហើយបានចាត់ទុកព្រះពុទ្ធជាអាទិទេព ព្រះអង្គបរិនិព្វាននៅស្ថានមនុស្ស តែបានទៅកើតនៅស្ថានសួគ៌រង់ចាំជួយសង្គ្រោះមនុស្សសត្វ ។ ត្រង់នេះផ្ទុយពីពុទ្ធសាសនាហីនយានដែលពោលថា ព្រះពុទ្ធបរិនិព្វានបាត់ហើយ មិនត្រឡប់មកវិញទៀតឡើយ ទុកធម៌វិន័យសំរាប់មនុស្សសត្វប្រតិបត្តិតាម ។

ចំពោះព្រះពុទ្ធសាសនាមហាយាន យើងបានសង្កេតឃើញផែនការមួយរបស់ព្រះពុទ្ធសាសនាទីបេត៍ ហៅថាផែនការមៃត្រេយ៍ (Maitrey project) ដែលមានបរទេសខ្លះចូលរួមផង មានគម្រោងកសាងព្រះរូបពោធិសត្វ នាមព្រះមៃត្រេយ៍ នៅកុសិនារា ដែលជាកន្លែងព្រះពុទ្ធបរិនិព្វាននៅប្រទេសឥណ្ឌា មានកំពស់១៥២ម៉ែត្រ អស់តម្លៃ១៥០

លានដុល្លារ តាមរចនាបថទីបេត៍ ។ លើសពីនេះទៀត គេមានគំរោងអភិវឌ្ឍន៍នៅជុំវិញតំបន់នោះ ដើម្បីជួយអ្នកក្រីក្រឥណ្ឌា ដូចជាបង្កើតសាលារៀន មន្ទីរពេទ្យជាដើម ។ បើគេពិនិត្យមើលរូបភាពតាម DVD ដែលពយកនេះចែកផ្សាយហាក់ដូចជាបានកសាងស្ទើររួចអស់ហើយក្នុងគំរោងទឹកប្រាក់ជិតពីររយលានដុល្លារ ប៉ុន្តែបើតាមអ្នកធ្វើទស្សនកិច្ចនៅប្រទេសឥណ្ឌាក្នុងពេលថ្មីៗនេះ នៅកុសិនារា នៅតែងដែលគ្មានឃើញធ្វើអ្វីទ្បើយ ដូច្នេះបញ្ជាក់ថា ក្រុមនោះយក DVD មកផ្សាយគ្រាន់តែឃោសនារកប្រាក់ ពុំឃើញការពិតទ្បើយ ។ សូមពុទ្ធសាសនិកជនខ្មែរកុំច្រឡំថា ព្រះពោធិសត្វមេត្រៃយ៍របស់ព្រះពុទ្ធសាសនាមហាយាននេះ ដូចគ្នានឹងព្រះសិអារ្យមេត្រៃយ៍របស់ព្រះពុទ្ធសាសនាថេរវាទខ្មែរយើងទ្បើយ ។ ព្រះពោធិសត្វខ្លះរបស់ពុទ្ធសាសនាមហាយាន គឺជាតួអង្គព្រះពុទ្ធដែលមានសំរេចធម៌នៅស្ថានមនុស្ស ហើយទៅកើតនៅស្ថានសួគ៌រង់ចាំជួយសង្រ្គោះមនុស្សសត្វ មិនមែនបរិនិព្វានបាត់ទៅដូចព្រះពុទ្ធសាសនាថេរវាទទ្បើយ ។

វត្តខ្មែរ ពុទ្ធិការាមនៅវ៉ាស៊ិនតោន និងវត្តសុរិយារង្សីនៅហ្វីឡានៃសហរដ្ឋអាមេរិក បានអនុញ្ញាតឲ្យពួកនោះរៃបច្ច័យក្នុងវត្តរបស់ខ្លួន ដែលមិនអាចដឹងបានថា ពួកនោះយកបច្ច័យដែលរៃបាននោះយកទៅណាទេ ។ ក្នុងពិធីនោះ មានយកព្រះធាតុដែលគេអះអាងថា ជាព្រះសារីរិកធាតុនៃព្រះពុទ្ធមកតាំងជាច្រើន មានគ្រប់ខ្នាត ធំ តូច កណ្តាល មិនដឹងបានមកពីណា ពិតឬពុំពិតទ្បើយ ។ ដូច្នេះពុទ្ធបរិស័ទខ្មែរមុននឹងជឿអ្វីមួយ គប្បីប្រើបញ្ញាពិចារណាឲ្យយល់ច្បាស់លាស់ ជាពិសេសក្រុមអភិបាលនៃពុទ្ធិកសមាគមខ្មែររបស់វត្តនីមួយៗ ព្រោះជាអ្នកទទួលខុសត្រូវ កុំឲ្យដឹកនាំគេទៅរកផ្លូវខុស ។ ខ្មែរគោរពព្រះពុទ្ធត្រាស់ដឹង ពុំមែនគោរពព្រះពោធិសត្វដែលជាបុថុជ្ជនទ្បើយ ។ មួយទៀត បើចង់កសាងត្រូវនាំគ្នាកសាងវត្តខ្មែរនៅក្រៅប្រទេស និងក្នុងមាតុភូមិរបស់យើងតែម្តង ។

## គណៈមាហានិកាយ និង គណៈធម្មយុត្តនៅកម្ពុជា

ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា គឺព្រះពុទ្ធសាសនាថេរវាទមាននិកាយពីរ គឺគណៈមហានិកាយ មានអ្នកកាន់ដ៏ច្រើនលើសលប់ និងគណៈធម្មយុត្ត មានអ្នកកាន់តិចតួច ដែលនិកាយទាំងពីរនេះស្ថិតនៅក្នុងពុទ្ធសាសនាថេរវាទជាមួយគ្នា ។ ប្រទេសស្រីលង្កា ប្រទេសភូមា ប្រទេសនេប៉ាល់ និងប្រទេសកាន់ព្រះពុទ្ធសាសនាឯទៀត គ្មាននិយាយធម្មយុត្តទេ ។ ខ្មែរចម្លងយកធម្មយុត្តពីប្រទេសថៃ ចំណែកលាវដែលចំឡងយកធម្មយុត្តពីប្រទេសថៃដែរ តែឥឡូវនេះ គេបំបាត់និកាយនេះចោលហើយ នៅនិកាយតែមួយ គឺគណៈមហានិកាយ ។៚

❇ ❇

❇